# សំណៅចុះឈ្មោះអ្នកផ្តល់សេវានៃកម្មវិធីសេវា ការមើលថែទាំក្នុងផ្ទះ (IHSS)

## សូមមើលព័ត៌មានខាងក្រោមនេះឱ្យបានហ្មត់ចត់មុននឹង អ្នកចាប់ផ្តើមបំពេញសំណៅនេះ

យោងទៅលើច្បាប់រដ្ឋ បើសិនជា អ្នកត្រូវបានជាប់ទោសពីបទឧក្រិដ្ឋ ឬ ជាប់ពន្ធនាគារបន្ទាប់ពីការផ្តន្ទាទោសនៅក្នុងបទឧក្រិដ្ឋដែលបានបដិសេធណាមួយ នៅក្នុងកំឡុងពេល 10 ឆ្នាំកន្លងផុតទៅ អ្នកនឹងមិនមានលក្ខណសម្បត្តិចុះឈ្មោះធ្វើជាអ្នកផ្តល់សេវា ឬ ទទួលបានប្រាក់បង់ពីកម្មវិធី IHSS សំរាប់កិច្ចការផ្តល់សេវានានាបានទេ លើកលែងតែ មានការបញ្ជាក់ដំល្អិតមួយដែលមានរាយចុះនៅខាងក្រោមនេះ ។ គឺវាមានបទល្មើសព្រហ្មទណ្ឌដែលបានបដិសេធ ពីរប្រភេទ ។

- **បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 ដូចបានចែងនៅក្នុងបទបញ្ញាច្បាប់វែលហ្វែរ៍ និង ស្ថាប័ន (W&IC) ផ្នែក12305.81គឺ:**
  1. ការរំលោភបំពានលើក្មេងដែលបានបញ្ជាក់យ៉ាងច្បាស់ (ច្បាប់ព្រហ្មទណ្ឌ [PC] វគ្គលេខ 273a[a]*),
  2. ការរំលោភបំពានលើមនុស្សចាស់ ឬ មនុស្សពេញវ័យនៅក្រោមបន្ទុក (ច្បាប់ព្រហ្មទណ្ឌ [PC] វគ្គលេខ 368*), និង
  3. ការគៃបន្លំលើកម្មវិធីថែទាំសុខភាព ឬ សេវាសុខភាពដែលឧបត្ថម្ភដោយថវិការដ្ឋ ។

- **បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ដូចបានចែងនៅក្នុងបទបញ្ញាច្បាប់វែលហ្វែរ៍ និងស្ថាប័ន (W&IC) ផ្នែក 12305.87 គឺ:**
  1. បទឧក្រិដ្ឋដ៏ឃោរឃៅ ឬ ដ៏ធ្ងន់ធ្ងរ ដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌ [PC] ] វគ្គលេខ 667.5(c)*, និង ច្បាប់ព្រហ្មទណ្ឌ [PC] ] វគ្គលេខ 1192.7(c)*,
  2. បទល្មើសឧក្រិដ្ឋដែលតំរូវឱ្យមនុស្សម្នាក់ចុះក្នុងបញ្ជីឈ្មោះជាអ្នកប្រព្រឹត្តបទល្មើសលើភេទ អនុលោមទៅតាមច្បាប់ព្រហ្មទណ្ឌ [PC] ] វគ្គលេខ 290(c)*, និង
  3. បទឧក្រិដ្ឋក្នុងការគៃបន្លំប្រាក់ជំនួយនៃកម្មវិធីសេវាសង្គមកិច្ចសាធារណៈដូចដែលបានបញ្ជាក់ នៅក្នុងបទបញ្ញាច្បាប់វែលហ្វែរ៍ និងស្ថាប័ន (W&IC) ផ្នែក 10980(c)(2)* និង (g)(2)* ។

  បញ្ជីរាយឈ្មោះស្តីអំពីបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ដែលមានគ្រប់ទាំងអស់ គឺអាចទទួលយកបានដោយការស្នើសុំពីការិយាល័យ IHSS ខោនធី ឬ អ្នកមានសមត្ថកិច្ចសាធារណៈផ្នែក IHSS ។

*សូមមើលសំណៅ SOC 426C ដែលមានដាក់ភ្ជាប់មកជាមួយ សំរាប់អត្ថបទស្តីអំពីច្បាប់ព្រហ្មទណ្ឌ (PC) និង ផ្នែកទាក់ទងនឹងច្បាប់វែលហ្វែរ៍ និងស្ថាប័ននានា ។

- ជាផ្នែកនៃដំណើរការចុះឈ្មោះអ្នកផ្តល់សេវា IHSS អ្នកត្រូវដាក់ផ្តល់ក្រដាសផ្តិតម្រាមដៃ និង ធ្វើដំណើរឆ្លងកាត់ការឆែកសាវតាឧក្រិដ្ឋកម្ម ដែលគ្រប់គ្រងដោយក្រសួងយុត្តិធម៌នៃរដ្ឋកាលីហ្វ័រនីញ៉ា ។
- បើសិនជា ដោយសារចម្លើយរបស់អ្នកនៅលើសំណៅនេះ ឬ ជាលទ្ធផលនៃការឆែកសាវតាឧក្រិដ្ឋកម្មបង្ហាញថា អ្នកធ្លាប់បានត្រូវគេផ្តន្ទាទោស ឬ បានជាប់ពន្ធនាគារ បន្ទាប់ពីការដាក់ទោសសំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 ឬមួយក៏បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ក្នុងកំឡុង ពេល 10 ឆ្នាំកន្លងផុតទៅ អ្នកនឹងមិនមានលក្ខណសម្បត្តិចុះឈ្មោះធ្វើជា អ្នកផ្តល់សេវា IHSS ឬ ទទួលបានប្រាក់បង់ពី កម្មវិធី IHSS សំរាប់កិច្ចការផ្តល់សេវានានា បានឡើយ ។
- សំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 បើសិនជា អ្នកបានទទួលលិខិតនីតិសម្បទា ឬ លិខិតនៃការលុបចោល (ការបញ្ចប់ក្តី អនុលោមទៅតាមច្បាប់ព្រហ្មទណ្ឌ (PC) ] វគ្គលេខ 1203.4) ការប្រព្រឹត្តបទឧក្រិដ្ឋ នឹងមិនធ្វើឱ្យអ្នកមិនមានលក្ខណសម្បត្តិទទួលកិច្ចការជាអ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះនៃ IHSS នោះឡើយ ។
- បើការផ្តន្ទាទោសរបស់អ្នកគឺសំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 អ្នកប្រហែលជាមានសិទ្ធិទទួល បាន ការស្នើសុំសំបុត្រលះបង់សិទ្ធិផ្ទាល់ខ្លួន ឬ សំបុត្រលើកលែងជាទូទៅ ក្រោមស្ថានភាពជាក់ ស្តែងដូច មានរៀបរាប់នៅខាង ក្រោមនេះ ។
- **មិនមានការអនុញ្ញាតឱ្យ នូវសំបុត្រលះបង់សិទ្ធិ ឬសំបុត្រលើកលែង សំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 នោះទេ ។**

សូមមើលនៅទំព័របន្ទាប់

# សំណៅចុះឈ្មោះអ្នកផ្តល់សេវា នៃកម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)

## សូមមើលព័ត៌មានខាងក្រោមនេះបន្តទៀតឱ្យបានហ្មត់ចត់មុននឹងអ្នកចាប់ផ្តើមបំពេញសំណៅនេះ

## ការលះបង់សិទ្ធិផ្ទាល់ខ្លួនក្នុងការមិនរាប់បញ្ចូលក្នុងការផ្តន្ទាទោសសំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2

បើសិនជា អ្នកត្រូវគេរកឃើញថាមិនមានលក្ខណសម្បត្តិ យោងទៅលើបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ដែលបានបដិសេធប៉ុន្តែ អ្នកទទួលជំនួយ IHSS (ឬ អ្នកតំណាងពេញច្បាប់របស់គាត់/នាង) មានបំណងជួលអ្នកឱ្យធ្វើជាអ្នក ផ្តល់សេវា ការមើលថែទាំក្នុងផ្ទះរបស់រូបគាត់/នាង ថ្វីបើ រូបអ្នកមានសារតាឧក្រិដ្ឋកម្ម ក៏ដោយ អ្នកប្រហែលជាអាចទទួលបានសំបុត្រស្នើសុំលះបង់សិទ្ធិមួយ ដែលមានចុះនៅផ្នែកខាងក្រោមនេះ ៖

- អ្នកទទួលជំនួយ IHSS ដែលមានបំណងជួលអ្នក (ឬ អ្នកតំណាងពេញច្បាប់របស់គាត់/នាង) នឹងត្រូវគេប្រាប់ឱ្យដឹងអំពីការផ្តន្ទាទោសរបស់អ្នក ហើយនឹងត្រូវគេប្រាប់ដោយផ្ទាល់ឱ្យរក្សាទុក ព័ត៌មាននៃការជាប់ទោសក្នុងបទឧក្រិដ្ឋនេះ ជាសម្ងាត់ ។
- អ្នកទទួលជំនួយដែលមានបំណងជួលអ្នកឱ្យធ្វើជាអ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះរបស់រូបគាត់/នាង (ឬ អ្នកតំណាងពេញច្បាប់របស់គាត់/នាង) ត្រូវផ្តល់សំណៅ (SOC 862) សេចក្តីស្នើសុំនៃអ្នកទទួលជំនួយ IHSS ក្នុងការលះបង់សិទ្ធិផ្ទាល់ខ្លួនសំរាប់អ្នកផ្តល់សេវា ទៅការិយាល័យ IHSS ខោនធី ឬ អាជ្ញាធរសាធារណៈផ្នែក IHSS ។
- សំបុត្រលះបង់សិទ្ធិ នឹងអនុញ្ញាតឱ្យអ្នកបានចុះឈ្មោះដើម្បីផ្តល់សេវាការមើលថែទាំក្នុងផ្ទះសំរាប់តែអ្នកទទួលជំនួយណាដែលបានស្នើសុំសំបុត្រលះបង់សិទ្ធិ តែប៉ុណ្ណោះ ។
- ប្រសិនបើអ្នក ជាអ្នកផ្តល់សេវា គឺជាអ្នកតំណាងពេញច្បាប់របស់អ្នកទទួលជំនួយផងដែរនោះ អ្នកមិនត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើការលើកលែង ក្នុងនាមតំណាងឱ្យអ្នកទទួលជំនួយ ដើម្បីលើកលែងបទឧក្រិដ្ឋទាំងឡាយណាដែលអ្នកត្រូវបានផ្តន្ទាទោសបានទេ។ ក្នុងករណីនេះ ការលើកលែងត្រូវតែចុះហត្ថលេខា ផ្ទាល់ដោយអ្នកទទួលជំនួយ ឬប្រសិនបើកិច្ចការនោះមិនអាចធ្វើទៅបាន មនុស្សម្នាក់ផ្សេងទៀតត្រូវតែបានប្រកាសថាជាអ្នកតំណាងពេញច្បាប់ ដើម្បីជាគោលបំណងនៃការចុះហត្ថលេខាលើការលើកលែងនេះ ។
- សំរាប់ព័ត៌មានបន្ថែមស្តីអំពីការស្នើសុំសំបុត្រលះបង់សិទ្ធិ អ្នកទទួលជំនួយ IHSS ដែលមានបំណងជួលអ្នកឱ្យធ្វើជាអ្នកផ្តល់សេវារបស់គាត់/នាង គួរតែទាក់ទងជាមួយនឹងការិយាល័យ IHSS ខោនធី ឬ អាជ្ញាធរសាធារណៈផ្នែក IHSS ។

## ការលើកលែងជាទូទៅក្នុងការមិនរាប់បញ្ចូលក្នុងការផ្តន្ទាទោសសំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2

បើសិនជា អ្នកត្រូវគេរកឃើញថាមិនមានលក្ខណសម្បត្តិ យោងទៅលើការជាប់ទោសក្នុងបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ដែលបានបដិសេធ ហើយ អ្នកចង់មានឈ្មោះចុះនៅក្នុងបញ្ជីចុះឈ្មោះអ្នកផ្តល់សេវា ឬ ដើម្បីផ្តល់សេវាការមើលថែទាំក្នុងផ្ទះដល់អ្នកអ្នកទទួលជំនួយ ដែលមិនបានស្នើសុំសំបុត្រលះបង់សិទ្ធិផ្ទាល់ខ្លួន ។

- អ្នកអាចដាក់ពាក្យសុំ សំរាប់ការលើកលែងជាទូទៅក្នុងការមិនរាប់បញ្ចូល ដោយបំពេញសំណៅ (SOC 863) សេចក្តីស្នើសុំការលើកលែងជាទូទៅរបស់អ្នកដាក់ពាក្យសុំផ្តល់សេវានៃ IHSS ។
- អ្នកនឹងត្រូវគេតម្រូវឱ្យផ្តល់នូវឯកសារគាំទ្រនានា ឧទាហរណ៍ ប្រវត្តិការងារ សំបុត្របញ្ជាក់ដែលយកជាសំអាង ។ ល ។ ដើម្បីគាំទ្រការស្នើសុំរបស់អ្នក សំរាប់ការលើកលែងជាទូទៅ ។
- សំរាប់ព័ត៌មានបន្ថែមស្តីអំពីការស្នើសុំសំបុត្រលើកលែងជាទូទៅ សូមទាក់ទងជាមួយនឹងការិយាល័យ IHSS ខោនធី ឬ អាជ្ញាធរសាធារណៈផ្នែក IHSS ។

សូមមើលនៅទំព័របន្ទាប់ →

# សំណៅចុះឈ្មោះអ្នកផ្តល់សេវា
# នៃកម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)

## ការណែនាំបង្ហាញ:

- សូមប្រើទឹកប៊ិចព៌ណខ្មៅ ឬ ខៀវសំរាប់បំពេញ ។ សូមសរសេរព័ត៌មានជាអក្សរពុម្ពឱ្យបានច្បាស់ ។
- សូមបំពេញ ចុះហត្ថលេខា និង ប្រគល់សំណៅនេះដោយទៅបង្ហាញខ្លួនផ្ទាល់នៅការិយាល័យ ឬ កន្លែងដែលបានជ្រើសរួចជាស្រេចដោយខោនធី ។ សូមនាំយកកាតសំគាល់ខ្លួននៃច្បាប់ដើម និង កាតសូស្យាល់សឺគូរីទីនៃច្បាប់ដើមរបស់អ្នក ដែលបានចេញដោយរដ្ឋាភិបាលសហព័ន្ធ ឬ រដ្ឋ មកជាមួយផង នៅពេលដែលប្រគល់សំណៅនេះ ។
- សូមបំពេញផ្នែក A ទាំងអស់, ឆ្លើយសំណួរនៅក្នុងផ្នែក B, ហើយពិនិត្យបញ្ជាក់ និង ចុះហត្ថលេខាលើសេចក្តីប្រកាសក្នុងផ្នែក C ។
- ខោនធីនឹង: 1) ពិនិត្យសំណៅនេះដោយហ្មត់ចត់ឡើងវិញ ដើម្បីឱ្យប្រាកដថា សំណៅនេះបានបំពេញចប់សព្វគ្រប់; 2) ធ្វើការចម្លងកាតសំគាល់ខ្លួន និង កាតសូស្យាល់សឺគូរីទីរបស់អ្នក; និង 3) ផ្តល់ជូនអ្នកវិញនូវសំណៅចម្លងដែលបំពេញចប់សព្វគ្រប់នេះ សំរាប់ជាឯកសាររបស់អ្នក ។
- អ្នកត្រូវតែប្រាប់ខោនធីឱ្យដឹង បើសិនជា សេចក្តីរាយការណ៍នៅលើសំណៅនេះមានការផ្លាស់ប្តូរ នៅក្នុងកំឡុងពេលដប់ (10) ថ្ងៃប្រក្រតិទិនពីថ្ងៃដែលដូរ ។

## ផ្នែក A: ព័ត៌មានស្តីពីអ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះ

| | | | |
|---|---|---|---|
| **1.** ឈ្មោះពេញ (ឈ្មោះផ្ទាល់ខ្លួន, ឈ្មោះកណ្តាល, ឈ្មោះត្រកូល): | **2.** ថ្ងៃកំណើត<br>បើ អ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកត្រូវតែផ្តល់ប័ណ្ណអនុញ្ញាតឱ្យធ្វើការដែលយកជាការបាំនដាក់មកជាមួយនឹងសំណៅនេះ ។ | | **3.** ភេទ:<br>☐ប្រុស ☐ស្រី |
| **4.** អាសយដ្ឋាន (ត្រូវតែជាអាសយដ្ឋានទទួលសំបុត្រពិតប្រាកដ **មិនមែន** ប្រអប់សំបុត្រប៉ុស្តិ៍ការិយាល័យប្រៃសណីយ៍នោះឡើយ): | ក្រុង: | រដ្ឋ:<br>CA | លេខស៊ីពកូដ: |
| **5.** អាសយដ្ឋានទទួលសំបុត្រ (បើសិនជា ផ្សេងពីអាសយដ្ឋានផ្ទះ)*: | ក្រុង: | រដ្ឋ:<br>CA | លេខស៊ីពកូដ: |
| **6.** លេខទូរស័ព្ទ (ព្រមទាំងលេខតំបន់): | **7.** លេខសូស្យាល់សឺគូរីទី**: | | |
| **8.** អាសយដ្ឋានអ៊ីម៉ែល (បើសិនជាអ្នកមាន អាសយដ្ឋានអ៊ីម៉ែលផ្សេងទៀត): | | | |
| **9. a.** លេខអាជ្ញាប័ណ្ណបើកបរ ឬ លេខអត្តសញ្ញាណប័ណ្ណចេញឱ្យដោយរដ្ឋាភិបាល: | **b.** ថ្ងៃផុតកំណត់:<br>**c.** រដ្ឋដែលបានចេញឱ្យ: | | |
| **10. a.** ភាសានិយាយដើមដំបូង: | **b.** ភាសាសរសេរដើមដំបូង: | | |

**កំណត់សំគាល់:**

* មូលប្បទានប័ណ្ណប្រាក់បៀវត្សរ៍សំរាប់អ្នកផ្តល់សេវាមិនអាចផ្ញើទៅ ប្រអប់សំបុត្រប៉ុស្តិ៍ការិយាល័យប្រៃសណីយ៍បានទេ លើកលែងតែខោនធីបានយល់ព្រមទទួលពាក្យស្នើសុំពីអ្នកផ្តល់សេវា ។

** ការទារយកលេខសូស្យាល់សឺគូរីទី គឺជាសេចក្តីតម្រូវដែលបានអនុលោមទៅតាមច្បាប់ W&IC 12305.81(a), និង the Immigration Reform and Control Act of 1986, Public Law 99-603 (8 USC 1324a), សំរាប់ជាគោលការណ៍ក្នុងការបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលនិមួយៗ និង ការផ្តល់សិទ្ធិអោយធ្វើ ការងារនៅក្នុងសហរដ្ឋអាមេរិក (United States) ។

សូមមើលនៅទំព័របន្ទាប់ →

# សំណៅចុះឈ្មោះអ្នកផ្តល់សេវា នៃកម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)

ឈ្មោះអ្នកផ្តល់សេវា: ____________________

## ផ្នែក B: សេចក្តីថ្លែងបញ្ជាក់របស់អ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះ

**សូមឆ្លើយនូវសំណួរខាងក្រោមនេះ ដោយគូសក្នុងប្រអប់ដែលសមរម្យ:**

**1. នៅក្នុងកំឡុងពេល 10 ឆ្នាំកន្លងផុតទៅនេះ តើអ្នកមានធ្លាប់ -**

**a.** បានជាប់ទោស ឬ បានជាប់ពន្ធនាគារបន្ទាប់ពីការផ្តន្ទាទោសសំរាប់បទល្មើស ព្រហ្មទណ្ឌថ្នាក់ទី 1* ឬទេ?........ ☐ បាទ/ចាំះ ☐ ទេ

**b.** បានជាប់ទោស ឬ បានជាប់ពន្ធនាគារបន្ទាប់ពីការផ្តន្ទាទោសសំរាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2* ឬទេ?......... ☐ បាទ/ចាំះ ☐ ទេ

*សូមមើលទំព័រទី 1 នៃសំណៅនេះសំរាប់អត្ថន័យស្តីអំពីបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 និង បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ។

**2. បើសិនជា អ្នកឆ្លើយថា "បាទ/ចាំះ" ទៅនឹងសំណួរ 1.b. ខាងលើនេះ** តើអ្នកមានទទួលបានលិខិតនីតិសម្បទា ឬ លិខិតនៃការលុបចោល (ការបញ្ចប់ក្តីអនុលោមទៅតាមច្បាប់ព្រហ្មទណ្ឌ (PC) ផ្នែក 1203.4) ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ឬទេ?...... ☐ បាទ/ចាំះ ☐ ទេ

*បើសិនជា បាទ/ចាំះ អ្នកត្រូវតែផ្តល់នូវឯកសារចម្លងលិខិតនីតិសម្បទា ឬ ផ្តល់នូវឯកសារនៃការលុបចោលពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 មកឱ្យខោនធី ជាមួយសំបុត្រដែលបំពេញចប់សព្វគ្រប់នេះ ។*

## ផ្នែក C: សេចក្តីថ្លែងប្រកាសរបស់អ្នកផ្តល់សេវា

### ខ្ញុំយល់ និង យល់ព្រមថា -

- ខ្ញុំមិនអាចទទួលប្រាក់ដែលជាថវិការរបស់កម្មវិធី IHSS ដែលជាប្រាក់បង់សំរាប់សេវាដែលបានអនុញ្ញាត ដែលខ្ញុំផ្តល់ទៅឱ្យអ្នកទទួលជំនួយណាម្នាក់ដែលមានលក្ខណសម្បត្តិទទួលជំនួយនៃ IHSS បានទេ លុះត្រាតែខ្ញុំបានបំពេញដំណើរការចុះឈ្មោះអ្នកផ្តល់សេវាឱ្យបានចប់សព្វគ្រប់និងខ្ញុំត្រូវបានចុះឈ្មោះត្រឹមត្រូវតាមផ្លូវការក្នុងការធ្វើជាអ្នកផ្តល់សេវា ដូចដែលបានតម្រូវដោយខោនធី ។
- ខ្ញុំមានរយៈពេល 90 ថ្ងៃ ចាប់ពីថ្ងៃដែលខ្ញុំបានចាប់ផ្តើមដំណើរការចុះឈ្មោះធ្វើជាអ្នកផ្តល់សេវាក្នុងការបំពេញតម្រូវការទាំងអស់នៃការចុះឈ្មោះជាលើកដំបូង។ បើសិនជា ខ្ញុំមិនបានបំពេញសេចក្តីតម្រូវលើការចុះឈ្មោះអ្នកផ្តល់សេវាឲ្យបានចប់សព្វគ្រប់ទាំងអស់ ក្នុងអំឡុង 90 ថ្ងៃនោះទេ ខ្ញុំនឹងត្រូវបានចាត់ទុកថាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការជាអ្នកផ្តល់សេវានៅក្នុងកម្មវិធី IHSS ហើយនិងមិនអាចទទួលបានប្រាក់បង់ពីកម្មវិធី IHSS សម្រាប់ការផ្តល់សេវាដែលបានអនុញ្ញាតទៅឲ្យអ្នកទទួលជំនួយ IHSS បានឡើយ។
- ជាផ្នែកនៃដំណើរការចុះឈ្មោះអ្នកផ្តល់សេវា ខ្ញុំត្រូវផ្តល់ក្រដាសដាក់ផ្តិតម្រាមដៃ និង ធ្វើដំណើរឆ្លងកាត់ការឆែកសាវតាឧក្រិដ្ឋកម្ម ។ ខ្ញុំនឹងទទួលខុសត្រូវលើការចំណាយសំរាប់ថ្លៃផ្តិតម្រាមដៃ និង ថ្លៃឆែកពិនិត្យសាវតា ។
- បើសិនជាវាត្រូវបានគេរកឃើញ ដោយការផ្តល់ចម្លើយរបស់ខ្ញុំនៅលើសំណៅនេះ ឬមួយក៏ជាលទ្ធផលនៃការឆែកសាវតាឧក្រិដ្ឋកម្ម ឬ ដោយសារអ្វីមួយផ្សេងទៀត ដែលកើតឡើងនៅក្នុងកំឡុងពេល 10 ឆ្នាំកន្លងផុតទៅ ដែលខ្ញុំត្រូវបានជាប់ចោទ ឬបានជាប់ពន្ធនាគារ បន្ទាប់ពីត្រូវបានទទួលការផ្តន្ទាទោស សំរាប់បទល្មើសព្រហ្មទណ្ឌដែលបានបដិសេធថ្នាក់ទី 1 ខ្ញុំនឹងមិនមានលក្ខណសម្បត្តិ ធ្វើជាអ្នក ផ្តល់សេវានៃ IHSS បានទេ ហើយ អ្នកទទួលជំនួយដែលមានបំណងជួលខ្ញុំ នឹងត្រូវគេប្រាប់ឱ្យដឹងថា ខ្ញុំមិនមានលក្ខណសម្បត្តិធ្វើជា អ្នកផ្តល់សេវាបានឡើយ ដោយសារតែ ការផ្តន្ទាទោសក្នុងបទឧក្រិដ្ឋដែលនឹងមិនបញ្ជាក់ឱ្យបានល្អិត ។ កំហុសនៃការផ្តន្ទាទោសក្នុង បទឧក្រិដ្ឋ ដែលនឹងមិន បញ្ជាក់ឱ្យបានល្អិត ។

សូមមើលនៅទំព័របន្ទាប់ →

# សំណៅចុះឈ្មោះអ្នកផ្តល់សេវា នៃកម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)

ឈ្មោះអ្នកផ្តល់សេវា:

## ផ្នែក C: សេចក្តីថ្លែងបញ្ជាក់របស់អ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះ (បន្ត)

### ខ្ញុំយល់ និង យល់ព្រមថា –

- បើសិនជាវាត្រូវបានគេរកឃើញដោយការផ្តល់ចម្លើយរបស់ខ្ញុំនៅលើសំណៅនេះ ឬមួយក៏ជាលទ្ធផលនៃការឆែកសារតាឧក្រិដ្ឋកម្ម ឬ ដោយសារអ្វីមួយផ្សេងទៀតដែលកើតឡើងនៅក្នុងកំឡុងពេល 10 ឆ្នាំកន្លងផុតទៅ ដែលខ្ញុំត្រូវបានជាប់ចោទ ឬបានជាប់ពន្ធនាគារបន្ទាប់ពីត្រូវបានទទួលការផ្តន្ទាទោសសំរាប់បទល្មើសព្រហ្មទណ្ឌដែលបានបដិសេធថ្នាក់ទី 2 និង ខ្ញុំមិនបានទទួលលិខិតនីតិសម្បទា ឬ លិខិតដែលថាការផ្តន្ទាទោសរបស់ខ្ញុំត្រូវបានលុបចោលនោះ:-
  - ខ្ញុំនឹងមិនមានលក្ខណសម្បត្តិធ្វើជាអ្នកផ្តល់សេវានៃ IHSS បានឡើយ លើកលែងតែ អ្នកទទួលជំនួយ IHSS ដែលមានបំណងជួលខ្ញុំដើម្បីផ្តល់សេវាការមើលថែទាំក្នុងផ្ទះដល់រូបគាត់/នាង ស្នើសុំការលះបង់សិទ្ធិផ្ទាល់ខ្លួនមួយ ឬក៏ ខ្ញុំដាក់ពាក្យស្នើសុំសំបុត្រលើកលែងជាទូទៅ និង ខ្ញុំបានទទួលការអនុញ្ញាត; និង
  - អ្នកទទួលជំនួយ IHSS ដែលមានបំណងជួលខ្ញុំឱ្យធ្វើជាអ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះរបស់គាត់/នាង នឹងត្រូវគេប្រាប់ឱ្យដឹងអំពីការផ្តន្ទាទោសរបស់ខ្ញុំ និង បទឧក្រិដ្ឋប្រភេទណាមួយដែលខ្ញុំត្រូវបានគេកាត់ឱ្យជាប់ទោស ហើយ គាត់/នាងនឹងត្រូវគេប្រាប់ឱ្យរក្សាទុកព័ត៌មាននេះជាសម្ងាត់ ។

### បើសិនជា ខ្ញុំត្រូវបានចុះឈ្មោះធ្វើជាអ្នកផ្តល់សេវា IHSS ដោយខោនធី

### ខ្ញុំយល់ និង យល់ព្រមថា -

- បើសិនជា មនុស្សដែលខ្ញុំផ្តល់សេវាការមើលថែទាំក្នុងផ្ទះ ទទួលជំនួយ IHSS តាមរយៈកម្មវិធី Medi-Cal ខ្ញុំនឹងត្រូវគេគិតថាជាអ្នកផ្តល់សេវា Medi-Cal សំរាប់កិច្ចការមើលថែទាំផ្ទាល់ខ្លួន ។ ហេតុដូច្នេះ ខ្ញុំនឹងត្រូវតម្រូវឱ្យធ្វើទៅតាមក្បួនច្បាប់នៃកម្មវិធី Medi-Cal ទាំងអស់ដែលមានទាក់ទងនឹងការផ្តល់កិច្ចការបំរើផ្សេងៗ ។
- ប្រាក់បង់សំរាប់សេវាដែលបានអនុញ្ញាត ដែលខ្ញុំផ្តល់ទៅឲ្យអ្នកទទួលជំនួយ IHSS នឹងត្រូវទទួលបានពីថវិការសហព័ន្ធ រដ្ឋ និង/ឬ ថវិការ IHSS របស់ខោនធី និង សេចក្តីថ្លែងការណ៍មិនពិតណាមួយ ដែលខ្ញុំផ្តល់ជូន រួមទាំងការចុះបញ្ជីពេលម៉ោងមិនត្រឹមត្រូវនៅលើតារាងពេល វេលាការងារ ឬ ការលាក់ទុកនូវព័ត៌មាន អាចនឹងត្រូវយកមកកាត់ទោសទៅតាមច្បាប់សហព័ន្ធ និង/ឬ ច្បាប់រដ្ឋ ។
- ខ្ញុំនឹងបង់សងទៅឲ្យកម្មវិធី IHSS វិញ សំរាប់ប្រាក់ដែលផ្តល់ឲ្យលើសចំនួនដែលបានបង់មកឲ្យខ្ញុំ ហើយនិង ប្រាក់ចេញឲ្យលើសចំនួនណាមួយ ដែលនឹងបង់ឲ្យជាបណ្តាក់ ឬ ទាំងអស់តែម្តង ដែលប្រហែលជាត្រូវដកចេញពីមូលប្បទានប័ណ្ណប្រាក់បៀវត្សរ៍នៅពេលខាងមុខនេះ សំរាប់សេវាការមើលថែទាំក្នុងផ្ទះដែលខ្ញុំបានផ្តល់ទៅអ្នកទទួលជំនួយនៃ IHSS ណាម្នាក់ ។
- ខ្ញុំនឹងផ្តល់ជូននូវកិច្ចការបំរើទាំងអស់ ដោយគ្មានប្រកាន់ពូជសាសន៍ សាសនា ពណ៌សម្បុរ សញ្ជាតិ ឬ ជាតិពន្ធដើម ភេទ វ័យ ចំណូលចិត្តលើផ្លូវភេទ ឬ អសមត្ថភាពខាងរាងកាយ ឬផ្លូវចិត្តទេ ។

**ខ្ញុំសូមប្រកាស ក្រោមច្បាប់នៃការផ្តន្ទាទោសលើបទភូតកុហកថា ព័ត៌មានទាំងអស់ដែលខ្ញុំបានផ្តល់អោយលើសំណៅនេះ គឺ ពិត និងត្រឹមត្រូវ យោងទៅតាមការយល់ដឹងដ៏ល្អបំផុតរបស់ខ្ញុំ ហើយ ខ្ញុំយល់ព្រមនូវសេចក្តីថ្លែងបញ្ជាក់ដែលមាននៅខាងលើនេះទាំងអស់ ។**

ហត្ថលេខា: ______________________ ខែថ្ងៃឆ្នាំ: ______________

សូមសរសេរឈ្មោះជាអក្សរពុម្ព: ______________________

**County Representative's Signature** (Optional): **DATE:**